# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០២២.......ន. គ. ស/.ណ.ស.ល

ថ្ងៃអង្គារ ១១ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង
## ស្តីពី
## គំរូលិខិតស្នើសុំផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

យោងតាមសេចក្តីណែនាំលេខ ០១០ ន.គ.ស. ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២២ ស្តីពីការអនុវត្តកាតព្វកិច្ចគណនេយ្យ និង សវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រង់ចំណុច (៣)ចែងថា “**អង្គភាពត្រូវស្នើសុំការអនុញ្ញាតពី ន.គ.ស. លើការកំណត់យកថ្ងៃបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ដែលបានកំណត់ដោយច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។ អង្គភាពត្រូវស្នើសុំការអនុញ្ញាតនេះ ឱ្យបានមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ សម្រាប់អង្គភាពដែលបានបង្កើតមុនថ្ងៃជូនដំណឹងនេះ។ ចំពោះអង្គភាពថ្មីបង្កើតឡើងក្រោយសេចក្តីណែនាំនេះ ត្រូវស្នើសុំមក ន.គ.ស. ក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីថ្ងៃចុះបញ្ជីជាស្ថាពរជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច។**” ដូច្នេះ ដើម្បីសម្រួលដល់ លោក លោកស្រី ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញក្នុងការស្នើសុំផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ **និយ័តករគណនេយ្យនិងសវនកម្ម** សូមផ្តល់ជូននូវគំរូលិខិតដូចបានភ្ជាប់មកជាមួយសេចក្តីជូនដំណឹងនេះស្រាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញមេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

**ប៊ុ ថារិន**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់ និយ័តករគណនេយ្យនិងសវនកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឈ្មោះអង្គភាពជាភាសាខ្មែរ÷

ឈ្មោះជាឡាតាំង ÷

លេខ អ.ត.ប. ÷

អាសយដ្ឋាន ÷

លេខទូរស័ព្ទ ÷

សារអេឡិចត្រូនិក ÷

**សូមគោរពជូន**

**ឯកឧត្តមអគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម**

**កម្មវត្ថុ**÷ សំណើស្នើសុំផ្លាស់ប្តូរកាលបរិច្ឆេទបិទបញ្ជីគណនេយ្យពីថ្ងៃទី៣១ ខែធ្នូ មកថ្ងៃទី......ខែ...... វិញ។

**យោង**÷ -អនុស្សរណៈយោគយល់គ្នារវាងក្រសួង-ស្ថាប័នមានសមត្ថកិច្ច

-លិខិតបញ្ជាក់ពីការិយបរិច្ឆេទគណនេយ្យរបស់អង្គភាពមេ

-បណ្ណប៉ាតង់ឆ្នាំចុងក្រោយ

-របាយការណ៍ហិរញ្ញវត្ថុឆ្នាំចុងក្រោយ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមអគ្គនាយក** មេត្តាជ្រាបថា÷ អង្គការ/សមាគមឈ្មោះ.................................... បានចុះបញ្ជី........................... នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានការគាំទ្រមូលនិធិធំជាងគេពីអង្គការ/សមាគមឈ្មោះ.................................... នៅប្រទេស............................... ដែលមានការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមនៅថ្ងៃទី........ខែ.........និងបញ្ចប់នៅថ្ងៃទី .........ខែ.........នៃឆ្នាំបន្ទាប់។

ដើម្បីងាយស្រួលដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមការិយបរិច្ឆេទគណនេយ្យរបស់អង្គការ/សមាគមមេនៅក្រៅប្រទេស ខ្ញុំបាទ/នាងខ្ញុំ សូមគោរពស្នើសុំ **ឯកឧត្តមអគ្គនាយក** ផ្លាស់ប្តូរកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី ៣១ ខែធ្នូ ទៅថ្ងៃទី........ខែ.........ដោយការិយបរិច្ឆេទគណនេយ្យថ្មីដំបូងរបស់អង្គការចាប់ផ្តើមពីថ្ងៃទី........ខែ.......ឆ្នាំ .........ដល់ថ្ងៃទី...... ខែ........ ឆ្នាំ..........។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមអគ្គនាយក** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គនាយក** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពី ខ្ញុំបាទ/នាងខ្ញុំ

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធានអង្គការ/សមាគម**

៤៤